# ករណីសិក្សានៅតុលាការកូនកាត់

## មេរៀនទទួលបានពីការវិវត្តន៍របស់ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិនៅកូសូវ៉ូ[1]

## ថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៦

ករណីសិក្សានេះគឺមានគោលបំណងផ្តល់ព័ត៌មានគ្រឹះ និងការវិភាគគោលនយោបាយទៅលើការវិវត្តន៍របស់ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិនៅកូសូវ៉ូ ដែលកម្មវិធីនេះត្រូវបានបង្កើតឡើងនៅក្រោមបេសកកម្ម អ.ស.ប (UNMIK) នៅក្នុងឆ្នាំ ១៩៩៩ ។ វាជាផ្នែកនៃស៊េរីមួយដែលមានគោលបំណងផ្តល់ព័ត៌មាន និងការវិភាគលើគោលនយោបាយ និងបញ្ហាអនុវត្តជាក់ស្តែងដែលតុលាការ កូនកាត់នេះកំពុងប្រឈមមុខ។ តុលាការកូនកាត់នេះត្រូវបានបង្កើតឡើងនៅកូសូវ៉ូ ដោយបានដាក់បញ្ចូលសមត្ថភាពអន្តរជាតិទៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក។ មេរៀនដែលអាចទាញយកចេញពី បទពិសោធនេះត្រូវបានបែងចែកជាផ្នែកៗដូចខាងក្រោមនេះ :

- ប្រវត្តិសាវតាសង្ខេបនៃជម្លោះនៅកូសូវ៉ូ
- ប្រវត្តិនៃការបង្កើតកម្មវិធីសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិ (IJP)
- សេចក្តីរៀបរាប់ពីកម្មវិធី IJP
- យុទ្ធសាស្ត្រក្នុងការចោទប្រកាន់ និងការជ្រើសរើសរឿងក្តី
- ក្របខ័ណ្ឌច្បាប់
- ការចាត់ចែងរដ្ឋបាល និងការការពារសាក្សី
- តំលៃ និងប្រសិទ្ធិភាព
- ទំនាក់ទំនងជាមួយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងយន្តការយុត្តិធម៌អន្តរកាលដទៃទៀត

[1] ករណីសិក្សានេះត្រូវបានរៀបរៀងសរសេរឡើងដោយ Tom Perriello និង Marieke Wierda។ Laura Dickinson បានចូលរួមជួយដល់សេចក្តីព្រាងដំបូង។ Tom Perriello បានធ្វើដំណើរទៅកាន់កូសូវ៉ូនៅក្នុងវិច្ឆិកា ឆ្នាំ២០០៣ ក្នុងគោលបំណងនៃការសិក្សានេះ។ ទស្សនៈដែលបានលើកឡើងនៅទីនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ មិនមែនជាទស្សនៈរបស់ ICTJ នោះទេ។ យើងខ្ញុំសូមថ្លែងចំពោះ Richard Rogers, Ayumi Kusafuka, Mark Freeman Annie Bird និង Vita Onwuasoanya ដែលបានជួយដល់ការធ្វើបច្ចុប្បន្នភាព និងការពិនិត្យការសិក្សានេះឡើងវិញ។

- ការផ្សព្វផ្សាយ ទស្សនៈយល់ឃើញរបស់សាធារណៈជន និងភាពជាកម្មសិទ្ធិ
- យុទ្ធសាស្ត្រច្រកចេញ និងកេរ្តិ៍មរតក ។

គោលបំណងនៃករណីសិក្សានេះ គឺដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋានទៅលើផ្នែកទាំងនេះក្នុងការជួយដល់អ្នកធ្វើគោលនយោបាយ និងដៃគូពាក់ព័ន្ធនៅក្នុងការបង្កើត និងការអនុវត្តន៍យន្តការស្រដៀងគ្នានេះ ព្រោះព័ត៌មានខ្លះមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយទេ។

## សេចក្តីសន្និដ្ឋានជាសង្ខេប

កូសូវ៉ូកំពុងឈានចូលដល់ឆ្នាំទីប្រាំមួយរបស់ខ្លួន ក្រោយពីជម្លោះជាតិសាសន៍ដ៏តឹងតែង ការរើសអើងជាប្រព័ន្ធ ដែលអូសបន្លាយរយៈពេលវែង និងការដាក់បញ្ចូលប្រព័ន្ធច្បាប់អន្តរជាតិ ទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួនដែលមានរយៈពេលប្រាំឆ្នាំមកហើយ។ ការបង្កើតផ្នែកផ្សេងៗដែលមានចៅក្រមអន្តរជាតិ (IJs) និងព្រះរាជអាជ្ញាអន្តរជាតិ (IPs) ទៅក្នុងប្រព័ន្ធច្បាប់នៅកូសូវ៉ូ ត្រូវបានគេយល់ថាជាផ្នែកមួយនៃការវិវត្តន៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងតថភាពខាងនយោបាយនៃស្ថានភាពក្រោយជម្លោះភ្លាម ដែលខុសគ្នាទៅនឹងគំនិតផ្តួចផ្តើមផ្នែកយុត្តិធម៌ ផែនការដែលបានរៀបចំ ឬគំនិតផ្តួចផ្តើមផ្នែកយុត្តិធម៌ដែលជាយុទ្ធសាស្ត្រអន្តរកាល ដើម្បីដោះស្រាយឧក្រិដ្ឋកម្មក្នុងអតីតកាល។ ប្រព័ន្ធនេះបានធ្វើឲ្យដំណើរឆ្ពោះទៅមុខមានការរអាក់រអួល ទោះបីជាការចូលរួមរបស់ប្រព័ន្ធនេះត្រូវបានកំរិតដោយការព្រួយបារម្ភផ្នែកខាងសន្តិសុខដែលនៅតែបន្ត គឺការព្រួយបារម្ភទាក់ទិនទៅនឹងឯករាជ្យ ផែនការពិសេស និងការអនុវត្តន៍ដ៏ទន់ខ្សោយ រួមទាំងអវត្តមាននៃផែនការជាក់ស្តែងមួយចំនួនសម្រាប់ការផ្ទេរ។

- **ផលប៉ះពាល់:** មានមនុស្សជាច្រើនរំពឹងថា ការបញ្ចូលប្រព័ន្ធច្បាប់អន្តរជាតិតាមរយៈកម្មវិធី (IJP) នៅកូសូវ៉ូ អាចនាំឲ្យមានផលប៉ះពាល់ដែលកាន់តែរីករាលដាលធំឡើង ដែលមកដល់ពេលនេះ ប្រសិទ្ធិភាពរបស់កម្មវិធីនេះត្រូវបានកំរិត ជាពិសេស ចំពោះការជំនួសសមត្ថភាពច្បាប់ក្នុងស្រុក ជាជាងការធានារ៉ាប់រងទៅវិញនោះ។ កត្តាចំបងគឺការដកចេញតួអង្គក្នុងស្រុកពីបញ្ហាគោលនយោបាយដែលទាក់ទងនឹងយុត្តិធម៌។ ជាប្រសិទ្ធិភាព កម្មវិធី IJP ដំណើរការដូចជា ប្រព័ន្ធប្រហាក់ប្រហែលមួយ ដោយផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើរឿងក្តីដែលមានលក្ខណៈរសើប រួមទាំង បទល្មើសដែលមានអង្គការចាត់តាំង ការជួញដូរគ្រឿងញៀន

ឬអំពើពុករលួយ ដែលបានប្រព្រឹត្តឡើងដោយមានខ្សែបណ្តាញ ដែលគាំទ្រតាមរយៈបក្សពួកមានអំណាចរបស់កូសូវ៉ូ ដែលចៅក្រមក្នុងស្រុកមានការស្ទាក់ស្ទើរក្នុងការកាត់ក្តី។

- **ធម្មានុរូប:** ប្រព័ន្ធ IJP បានបំផុសឱ្យមានការយកចិត្តទុកចិត្តក្នុងកំរិតមួយជាក់លាក់នៅក្នុងប្រព័ន្ធច្បាប់ ជាពិសេស នៅក្នុងការការចាត់ចែងរឿងក្តីជាអន្តរជាតិ ជាជាងប្រព័ន្ធក្នុងស្រុក។ អ្នកមានវិជ្ជាជីវៈច្បាប់ក្នុងស្រុកយល់ស្របថា កម្មវិធី IJP មានសារៈសំខាន់ និងបន្តបំរើគោលបំណងដ៏មានតម្លៃមួយ ប៉ុន្តែ តម្រូវការដែលនៅតែបន្តមានសម្រាប់បុគ្គលិកជនបរទេស អាចនាំឱ្យមានការអន្តរាយដល់ទំនុកចិត្តក្នុងស្រុកដែលអូសបន្លាយរយៈពេលវែងនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក។ ជាមួយគ្នានេះផងដែរ ជនជាតិក្នុងស្រុកត្រូវបានដកចេញពីការរៀបចំតាក់តែងកម្មវិធី និងសេចក្តីសម្រេចសំខាន់ៗ ដែលធ្វើឡើងនៅក្នុងពេលនៃការអនុវត្តន៍របស់ខ្លួន។
- **ឯករាជ្យភាព:** កម្មវិធី IJP ខ្លួនឯង និងការខិតខំប្រឹងប្រែងរបស់បុគ្គលិកបរទេសម្នាក់ៗ អាចនាំឱ្យទទួលបាននូវវិធានការមួយនៃការជឿទុកចិត្តនៅក្នុងកូសូវ៉ូ ដែលជាឆន្ទានុសិទ្ធិនៃអំណាចប្រតិបត្តិដ៏ទូលំទូលាយរបស់ UNMIK មកលើបញ្ហាតុលាការ ដែលនាំឱ្យមានការរីករាលដាលនូវទស្សនៈមកលើឯករាជ្យភាព និងជាការរារាំងដល់ការបង្កើតឱ្យមានការគោរពច្បាប់។ ក្របខ័ណ្ឌដ៏ត្រឹមត្រូវមួយក្នុងការបំភ្លឺពីអំណាចទាំងនេះ អាចជួយកាត់បន្ថយដល់ទស្សនៈនៃអំណាចតាមទំនើងចិត្ត និងការជ្រៀតជ្រែកដែលមិនសមស្រប។
- **ភាពត្រឹមត្រូវ:** ក្នុងខណៈដែល IJP មានសារៈប្រយោជន៍នៅក្នុងការធានាសម្រេចឱ្យបាននូវយុត្តិធម៌នៅក្នុងរឿងក្តីរបស់បុគ្គលម្នាក់ៗ នោះជំហររបស់ពួកគេមិនចាំបាច់នាំទៅដល់វិធានការចាំបាច់នៃភាពត្រឹមត្រូវនៅក្នុងសវនាការនោះទេ។ ក្របខ័ណ្ឌច្បាប់សព្វថ្ងៃមានភាពស្មុគស្មាញ និងត្រូវការការបណ្តុះបណ្តាលទាំងអ្នកដែលមានវិជ្ជាជីវៈច្បាប់ជាតិ និងអន្តរជាតិជាបន្ត ដែលជាប្រយោជន៍នាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយគុណភាពកាន់តែប្រសើរឡើង។ ការអនុវត្តអនុសញ្ញាសហភាពអឺរ៉ុបស្តីពីសិទ្ធិមនុស្សដោយផ្ទាល់ អាចនាំឱ្យមានផលប៉ះពាល់ជាវិជ្ជមានដល់ភាពត្រឹមត្រូវក្នុងពេលមួយ។ ប៉ុន្តែ OSCE ដែលកំពុងឃ្លាំមើលដំណើរការនេះបានបន្តស្វែងរកឱ្យឃើញថា ការវិវត្តន៍ទាំងនេះគឺត្រូវការនៅក្នុងផ្នែក

សំខាន់ៗ[2] នៅក្នុងការកាត់សេចក្តីក្នុងស្រុក។ ទស្សនៈទាននៃភាពត្រឹមត្រូវបន្តបែងចែកក្នុងចំណោមជាតិពន្ធ។ ការខ្វះខាតនូវយុទ្ធសាស្ត្រដែលសកម្មជាមុនរបស់ UNMIK បានបង្កជាឧបសគ្គដល់តម្លាភាពនៃកម្មវិធី IJP និងបេសកកម្មនេះបានបាត់បង់ឱកាសដល់ការធ្វើឲ្យលេចចេញនូវរូបរាងឡើងនូវ ទស្សនៈទាន និងការរំពឹងទុក ។

- **ប្រសិទ្ធិភាពទូទៅ:** ចំនួនរឿងក្តីដែលបានកាត់នៅកូសូវ៉ូ គឺអាចប្រៀបធៀបបានទៅនឹងប្រព័ន្ធក្នុងស្រុកដទៃទៀត។ ក្នុងខណៈដែលចៅក្រម និងព្រះរាជអាជ្ញាជាតិមួយចំនួនបញ្ចេញទស្សនៈថា ការចូលរួមរបស់អន្តរជាតិបាននាំឲ្យការកាត់សេចក្តីមានការយឺតយ៉ាវ តែដំណើរការរឿងក្តីព្រហ្មទណ្ឌធំៗ និងដែលត្រូវការពិភាក្សាកាន់តែច្រើន អាចមានប្រយោជន៍។
- **កេរ្តិ៍មរតក:** ទោះបីជាប្រព័ន្ធ IJP មិនបានកើនឡើងយ៉ាងច្រើននៅក្នុងចំណោមរឿងក្តីសរុបក៏ដោយ ក៏វាអាចត្រូវបានគេមើលឃើញថាមិនមានប្រសិទ្ធិភាពនោះទេ ប្រសិនបើវាមិនមានលទ្ធផលនៅក្នុងផលប៉ះពាល់ជាប្រព័ន្ធនៃកេរ្តិ៍មរតកទេ។ ម្យ៉ាងវិញទៀត ការរំពឹងទុកពីអ្វីដែលអាចត្រូវបានសម្រេចឲ្យស្របច្បាប់នៅក្នុងការផ្លាស់ប្តូរជាប្រព័ន្ធនៅក្នុងរយៈពេលតែប្រាំមួយឆ្នាំប៉ុណ្ណោះនោះ អាចជាសុទិដ្ឋិនិយមមួយ។ ប៉ុន្តែ វាចាំបាច់ណាស់ថា គួរអនុញ្ញាតឲ្យមានការកែតម្រូវសម្រាប់ការកែប្រែជាប្រព័ន្ធចាប់ពីពេលនេះតទៅ។

កង្វះខាតធនធាន និងការស្វែងរកបុគ្គលិកអន្តរជាតិដែលមានលក្ខណៈសម្បត្តិសមរម្យ (និងបានទទួលការបណ្តុះបណ្តាល) គឺជាឧបសគ្គលេចធ្លោ បើទោះបីជាចំនុចនេះប្រហែលជាផលិតផលមួយនៅក្នុងលក្ខណៈដែល IJP បានវិវត្ត និងបានរីកចំរើនក៏ដោយ។ អ្នកខ្លះអាចជំទាស់ថា ប្រព័ន្ធសមត្ថភាពអន្តរជាតិមួយដែលផ្តោតទៅលើថ្នាក់កណ្តាលកាន់ខ្លាំង អាចជៀសវាងនូវបញ្ហាទាំងអស់នោះបានខ្លះដោយការបង្កើនលក្ខខណ្ឌនៃសេវា និងការធ្វើឲ្យបុគ្គលិកបរទេសមានអារម្មណ៍ឯកកោកាន់តែតិច។ អ្នកខ្លះទៀតអាចជំទាស់ចំពោះផលប្រយោជន៍នៃការពង្រីកបុគ្គលិកបរទេសនៅទូទាំងប្រព័ន្ធក្នុងស្រុក

---

[2] សូមមើល ឧទាហរណ៍ អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) ផ្នែកឃ្លាំមើលប្រព័ន្ធច្បាប់ (LSMS) "ការពិនិត្យមើលប្រព័ន្ធយុត្តិធម៌ឡើងវិញ" (ខែមេសា ឆ្នាំ២០០៣ ដល់ ខែតុលាឆ្នាំ២០០៤) ស្តីពី បទល្មើសការឃុំឃាំង និងការផ្តន្ទាទោស។

បើទោះបីជាការកសាងសមត្ថភាពមិនត្រូវបានធ្វើដល់កំរិតអតិបរមាក៏ដោយ ហើយទំនាក់ទំនងរវាងបុគ្គលិកអន្តរជាតិ និងបុគ្គលិកជាតិ អាចក្លាយជាយុទ្ធសាស្ត្រកាន់តែខ្លាំងឡើង។

អ្នកសង្កេតការណ៍បានកត់សំគាល់ថា សមត្ថភាពបុគ្គលិកក្នុងស្រុកនៅកូសូវ៉ូក្នុងការកាត់សេចក្តីរឿងក្តីដែលស្មុគស្មាញ និងមានលក្ខណៈនយោបាយនៅមានកំរិតនៅឡើយ។ ប្រព័ន្ធ IJP នៅកូសូវ៉ូ ប្រហែលជាត្រូវការឲ្យបន្តមានសម្រាប់អនាគតមួយដែលអាចធ្វើទៅបាន។ ចំនុចនេះធ្វើឲ្យកំរិតនៃទំនុកចិត្តមានការកើនឡើងតិចតួចនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក។ ការពង្រីកនូវការចូលរួមពីអន្តរជាតិអាចផ្តល់ឱកាសថ្មីដើម្បីដឹកនាំការខិតខំប្រឹងប្រែងឡើងវិញដោយមានលក្ខណៈជាយុទ្ធសាស្ត្រកាន់តែខ្លាំងឡើង។ វិធីមួយដែលនឹងត្រូវបង្កើតឡើង គឺការផ្តោតកាន់តែខ្លាំងទៅលើការផ្ទេរជំនាញ និងការប្រគល់ជាយថាហេតុដើម្បីធ្វើការឆ្ពោះទៅកាន់យុទ្ធសាស្ត្របញ្ចប់កម្មវិធី IJP ។

អ្នកប្រកបវិជ្ជាជីវៈច្បាប់នៅកូសូវ៉ូគួរត្រូវបានចូលរួមទាំងស្រុងនៅក្នុងការរៀបចំយុទ្ធសាស្ត្រ ដោយកែប្រែវប្បធម៌នៃការខ្វះការពិគ្រោះយោបល់សព្វថ្ងៃនេះ។ វាក៏មានសារៈសំខាន់ផងដែរដែលអ្នកតាក់តែងគោលនយោបាយអន្តរជាតិគួរចាប់ផ្តើមផ្តោតការខិតខំប្រឹងប្រែងរបស់ខ្លួនដោយធានាថា ការយល់ដឹងរបស់សាធារណៈជនមកលើកំរិតនៃប្រព័ន្ធនេះត្រូវបានកើនឡើង តាមរយៈការផ្សព្វផ្សាយប្រកបដោយការខិតខំប្រឹងប្រែង និងចំទិសដៅ និងការអប់រំសហគមន៍។ ជំហ៊ានទាំងអស់នេះត្រូវការនូវការពង្រឹងឲ្យអស់ពីសមត្ថភាពរបស់សហគមន៍អន្តរជាតិ និងធានាចំពោះផលប៉ះពាល់រយៈពេលវែងរបស់ខ្លួន៕